

សេរីការ

# មូលហេតុ នៃ សង្គ្រាម នៅ សាធារណរដ្ឋខ្មែរ

សរសេរ ដោយ លោក ចាច់ តែន

ធ្លាប់ចុះផ្សាយ ក្នុងកាសែត « ខ្មែរសាធារណរដ្ឋ » ថ្ងៃសៅរ៍ ទី១៦ វិច្ឆការ ១៩៧៤

សង្គ្រាមឈ្លានពាន ដែល បង្កើតឡើង ដោយពួកកុម្មុយនិស្តឥណ្ឌូចិន មានយួនខាងជើង ជា មេក្លោង និង ចិនកុម្មុយនិស្ត ជា អ្នកគាំទ្រនោះ កំពុង តែបន្ត ឥតស្រាកស្រាន្ត នៅប្រទេសយួនខាងត្បូង ទោះបី កិច្ចព្រមព្រៀងបញ្ចប់សង្គ្រាម ត្រូវបាន ចុះហត្ថលេខា អស់រយៈពេល ជិតពីរឆ្នាំហើយក៏ដោយៗ ដោយឡែកនៅសាធារណរដ្ឋខ្មែរ សង្គ្រាមនេះ មាន សភាព កាន់តែសាហាវខ្លាំងឡើង រៀងរាល់ថ្ងៃទោះបី រដ្ឋាភិបាល សាធារណរដ្ឋខ្មែរ បាន ធ្វើសេចក្តីអំពាវនាវ មួយលើក ជា ពីរលើក សុំអញ្ជើញ ក្រុមខ្មែរម្ខាងទៀត ចូលរួម អង្គុយតុចរចា ដើម្បី បញ្ចប់ សង្គ្រាមដែល បាននាំមក នូវ ទុក្ខវេទនា ខ្លោចផ្សា ដល់ ប្រជារាស្ត្រខ្មែរស្លូតត្រង់ អស់ពេលជិត ៥ឆ្នាំ ហើយក៏ដោយៗ

## តើសង្គ្រាមនេះ កើតឡើងដោយសារអ្វី ? ក្នុងលក្ខណៈបែបណា ? និង ក្នុងគោលដៅអ្វីដែរ ?

មតិអន្តរជាតិ មួយភាគ ប្រហែល ជានៅមាន ការស្រពិចស្រពិល ក្នុងរឿងនេះនៅឡើយៗ រីឯមតិជាតិ មួយភាគតូច ក៏នៅពុំទាន់យល់ ឬ « ធ្វើមិនយល់ » ចំពោះរឿងនេះដែរៗ មុននឹង ទៅដល់ សេចក្តីសន្និដ្ឋាន ដើម្បី ជា ចម្លើយ ចំពោះ សំណួរខាងលើនេះ យើង សូមរំលឹក អំពី មូលហេតុ ធំចម្បង ពីរយ៉ាង នៃ សង្គ្រាម ដែលកើតឡើង នៅក្នុង សាធារណរដ្ឋខ្មែរ ជាង បួនឆ្នាំ មកហើយនេះៗ មូលហេតុធំ ទី

១ គឺ យួនខាងជើង ដែល ជា ប្រទេសកុម្មុយនិស្ត តែមួយគត់ នៅ ឧបទ្វីឥណ្ឌូចិន មាន បំណង ចង់ លេប ត្របាក់ ប្រទេស ទាំងបី នៅជិតខាងខ្លួន ដែល មិនមែន ជា កុម្មុយនិស្ត គឺ វៀតណាមខាងត្បូង លាវ និង ខ្មែរ ដើម្បី បញ្ចូល ប្រទេស ទាំងបី នេះ ទៅក្នុង « សហពន្ធ កុម្មុយនិស្ត ឥណ្ឌូចិន » ក្រោមការដឹកនាំ និង ត្រួតត្រាផ្ទាល់ របស់ យួនខាងជើង ស្រប តាមបណ្តាំ របស់ ខ្មោច ហូជីមិញ។ មូលហេតុ ធំ ទី២ គឺ សេចក្តីលោភលន់ ឥតព្រំដែន របស់ ស្តេចសីហនុ ដែល ត្រូវ ប្រជារាស្ត្រខ្មែរ ហួតងារ ពី តំណែងប្រមុខរដ្ឋ។ គឺ បណ្តាល មក ពី មូលហេតុ ធំ ពីរ នេះហើយ ដែល បាន ធ្វើឲ ប្រជារាស្ត្រខ្មែរ ដែល ជា ប្រជារាស្ត្រ ស្លូតត្រង់ ស្នេហាសន្តិភាព ប្រកាន់ យក នយោបាយ អព្យាក្រឹត និង កាន់ ព្រះពុទ្ធសាសនា ត្រូវ ទទួល រងគ្រោះ ដោយ អយុត្តិធម៌ ក្នុងសង្គ្រាម ឈ្លានពាន តាំងពី ឆ្នាំ ១៩៧០ រហូត មកទល់ថ្ងៃនេះ នៅ ពុំទាន់ចប់ នៅឡើយ។

## ហេតុអ្វី ក៏ មាន ការទម្លាក់ ស្តេចសីហនុ ចេញពី មុខតំណែង ?

ដើម្បី ឆ្លើយនឹង សំណួរនេះ យើង សូមវិល ទៅរក ប្រវត្តិសាស្ត្រ និង ព្រឹត្តិការណ៍ ធំៗ មុន ថ្ងៃ១៨ មីនា ១៩៧០។ ស្តេចសីហនុ បាន កាន់អំណាចផ្តាច់ការ អស់រយៈពេល១៥ឆ្នាំ។  ពីឆ្នាំ១៩៤១ដល់ឆ្នាំ១៩៥៥,សីហនុបានដឹកនាំប្រទេសក្នុងឋានៈជា មហាក្សត្រ។ ពី ឆ្នាំ ១៩៥៥ ដល់ ឆ្នាំ ១៩៦០ ជា រដ្ឋមន្ត្រីទី១។ ពី ឆ្នាំ ១៩៦០ ដល់ ឆ្នាំ ១៩៧០ ក្នុង ឋានៈ ជា ប្រមុខរដ្ឋ។ ហេតុអ្វី ក្នុងរយៈពេល ៣០ឆ្នាំ សីហនុ មាន ឋានៈ ជា មហាក្សត្រផង ជា រដ្ឋមន្ត្រីទី១ផង ហើយ ប្រមុខរដ្ឋផង យ៉ាងដូច្នេះ ?

រឿងនេះ គេ ពុំមានអ្វី គួរឲ ងឿងឆ្ងល់ទេៗ ដោយ ដឹង ថា ក្នុង ឋានៈ ជា មហាក្សត្រ អំណាច របស់ ខ្លួន ត្រូវ ឋិត នៅក្នុង ព្រំដែន ចង្អៀត ចង្អល់ ពី ព្រោះ កិច្ចការដឹកនាំរដ្ឋ ត្រូវ ធ្លាក់ ទៅក្នុង កណ្ដាប់ដៃ នៃ រដ្ឋមន្ត្រីទី១ ហើយ ដោយ មក ពី មើល ឃើញ ការវិវត្តន៍ របស់ សាកលលោកឆ្ពោះ ទៅ រក របបប្រជាធិបតេយ្យ បាន ជា នៅ ឆ្នាំ ១៩៥៥ ស្ដេចសីហនុ បានដាក់រាជ្យ ហើយ ផ្ទេរ ទៅឲឪពុក របស់ខ្លួនៗ ចំណែក សីហនុ ក៏ បាន តាំង ខ្លួនឯង ជា រដ្ឋមន្ត្រីទី១ វិញៗ បន្ទាប់ ពី ស្ដេច សុរាម្រិត ជា ឪពុក របស់ខ្លួន ស្លាប់ទៅ នៅ ឆ្នាំ ១៩៦០ ដោយ ពុំ បាន តែងតាំង ស្ដេច ណាមួយ គ្រង រាជ្យបន្ត សីហនុ ដែល បាន សម្រេចចិត្ត ដាក់ រាជ្យ នៅ ឆ្នាំ ១៩៥៥ ហើយ ស្បថស្បែរ ថា នឹងមិនឡើង សោយរាជ្យ ទៀតទេនោះ ក៏ បាន តាំងខ្លួន ជា « ប្រមុខរដ្ឋ » វិញ ដោយ បញ្ជា ឲ រដ្ឋសភាធ្វើ ការកែប្រែ រដ្ឋធម្មនុញ្ញ ឲស្របតាម បំណង លោភ អំណាច របស់ខ្លួន ចាប់ តាំង ពី ថ្ងៃ ទី១២ មិថុនា ឆ្នាំ ១៩៦០ រហូត ដល់ ថ្ងៃ ១៨ មីនា ១៩៧០ ដែល ត្រូវ ធ្លាក់ ពី តំណែង ដោយសារ តែ អំពើក្បត់ជាតិ របស់ខ្លួន ដែល ប្រជារាស្ត្រខ្មែរ ពុំអត់ឱនឲបានៗ ពី ព្រោះ ក្នុង កំឡុងពេល កាន់ អំណាច ជា ប្រមុខរដ្ឋផ្ដាច់ការ ដែល ឥតមាន កំណាត់ព្រំដែន អាណត្តិ និង អំណាចនោះ, សីហនុ បាន ចាត់ចែង កិច្ចការ និង នយោបាយ របស់ប្រទេសតាម តែ អំពើចិត្តៗ សីហនុ ចាត់ទុក យួនខាងជើង និង យៀកកុង ដែល ជា សត្រូវ របស់រាស្ត្រខ្មែរ ហើយ ដែល ធ្លាប់ បានលេបត្របាក់ ទឹកដីខ្មែរ អស់មួយនាគធំ កាល ពី អតីតកាលនោះ ថា ជា « បងប្អូន » និង ជា « មិត្ត » របស់ខ្លួនៗ ជា ពិសេស ចាប់ តាំង ពី ឆ្នាំ ១៩៦៥ សីហនុ បាន ក្បត់នឹង នយោបាយ អព្យាក្រឹតខ្មែរ

ដោយ អនុញ្ញាតឲ ទ័ពយួនខាងជើង និង យៀកកុង ចូលមកតាំង មូលដ្ឋានសឹកពាសពេញ ក្នុងទឹកដីខ្មែរ ជា ពិសេស ក្នុងខេត្តខ្មែរទាំងឡាយ នៅ ប៉ែកខាងកើតតាំង ពី រតនគីរី រហូត មាត់សមុទ្រ ដើម្បី ឲពួកនេះ ចេញទៅ វាយប្រហារ វៀតណាមខាងត្បូងៗ ក្រៅពីនេះ សីហនុ បាន អនុញ្ញាត ដោយ សម្ងាត់ ឲយួន ខាងជើង និង យៀកកុង ប្រើប្រាស់ កំពង់ផែ កំពង់សោម ដើម្បី ដឹកនាំ គ្រឿងអាវុធ និង គ្រាប់រំសេវ យក ទៅផ្ដល់ ឲកងទ័ព របស់ខ្លួន ធ្វើ សង្គ្រាមឈ្លានពាន នៅ វៀតណាមខាងត្បូងៗ ដោយ បាន សេចក្ដីអនុញ្ញាត ពី សីហនុ តាមរយៈ នៃ កិច្ចព្រមព្រៀងសម្ងាត់មួយ ពួកទ័ពយួនខាងជើង និង យៀកកុង ដែល ចូលមក តាំងទី នៅលើទឹកដីខ្មែរ បាន ប្រកាន់ ឫកពា ជា ម្ចាស់ លើទឹកដីនេះ តែម្ដងៗ ពួកគេ បាន លួចប្លន់ យក នោគផល របស់រាស្ត្រខ្មែរ តាម អំពើចិត្ត ដើម្បី យក ទៅ ចិញ្ចឹមទ័ពខ្លួនកំពុង ធ្វើ សង្គ្រាមនៅ វៀតណាមខាងត្បូងៗ មិនតែប៉ុណ្ណោះ ពួកឈ្លានពាន ទាំងនេះ បាន ធ្វើ បាបជិះជាន់ រាស្ត្រខ្មែរស្លូតត្រង់ ដែល មិនពេញចិត្តនឹងខ្លួន ដោយឥត មាន ការរអែងអ្វី សោះឡើយៗ នៅចំពោះមុខ សភាពការណ៍ បែបនេះ ប្រជារាស្ត្រខ្មែរ ជាពិសេស ប្រជាពលរដ្ឋ នៅ តំបន់ ទាំងឡាយ ដែល ទ័ពយួនខាងជើង និង យៀកកុង ចូល កាន់កាប់ កើត ក្ដីក្ដៅក្រហាយ យ៉ាងខ្លាំងៗ បាតុកម្ម ជា ច្រើនក៏បានផ្ទុះឡើង ប្រឆាំងនឹង វត្តមាន របស់ ទ័ពយួនខាងជើង និង យៀកកុង នៅលើទឹកដីខ្មែរៗ ជា ដំបូង បាតុកម្ម ផ្ទុះឡើង នៅ ខេត្តស្វាយរៀង នៅ ថ្ងៃ ទី៨ មីនា ១៩៧០ៗ នៅ ថ្ងៃ បន្ទាប់មក បាតុកម្ម របៀបនេះ ក៏ បាន រាលដាល មក ដល់ ក្រុងភ្នំពេញ និង ខេត្តក្រៅ ខ្លះទៀតៗ ជា ពិសេស នៅ ថ្ងៃ១១ មីនា ១៩៧០ បាតុកម្ម

ដ៏ គគ្រឹកគគ្រេង បាន ផ្ទុះឡើង ប្រៀបបាននឹង ទឹក ហូរ បាក់ទំនប់ ពុំ មាន អ្វី អាច ទប់ បាន ប្រឆាំងនឹង ស្ថានទូត យួនខាងជើង និង យៀកកុង នៅ កណ្ដាល ក្រុង ភ្នំពេញ តែម្ដងៗ ក្នុងបំណង សម្រុះសម្រួល នៅ ថ្ងៃ១២ មីនា រដ្ឋាភិបាលស្រោច ស្រង់ជាតិ កាលណោះ បាន ស្នើសុំឲ្យយួនខាងជើងនិងយៀកកុង,ដកកងកម្លាំង របស់ខ្លួនថយចេញពីទឹកដីខ្មែរឲអស់នៅត្រឹមថ្ងៃ១៥មីនា១៩៧០ៗ តែ យួនខាង ជើង និង យៀកកុង ឥតបានយកចិត្តទុកដាក់ ដល់ សេចក្ដីស្នើ របស់ ខ្មែរនេះទេៗ នៅ ព្រឹក ថ្ងៃ១៦ មីនា បាតុកម្ម ដ៏ធំមួយ ក៏បានផ្ទុះឡើង ជា ថ្មី ទៀត នៅ ក្រុង ភ្នំពេញ ទាមទារ ឲទ័ពយួនខាងជើង យៀកកុង ឆាប់ថយចេញ ជា ប្រពីទឹកដីខ្មែរៗ ដោយ ចង់ ដោះស្រាយ បញ្ហានេះ ឲបានឆាប់រហ័ស និង ដោយ សន្ដិវិធី រដ្ឋាភិបា លខ្មែរ ក៏ បាន ស្នើ បើក កិច្ចចរចាមួយ លើកទៀត នៅ ថ្ងៃ១៦ មីនា នេះជា មួយ នឹង ពួកតំណាង យួនខាងជើង និង យៀកកុង នៅភ្នំពេញៗ ប៉ុន្ដែ ដូច គេបានដឹង ស្រាប់ហើយថា,កិច្ចចរចានោះ ពុំ បាន ហុច ផល នូវ លទ្ធផល អ្វីបន្ដិចបន្តួចសោះ ទេ ដោយ ពួកខាង យួនកុម្មុយនិស្ដ នៅ តែ ប្រកាន់ អាកប្បកិរិយា រឹងត្អឹងនឹង លាក់ ពុតដដែល ជាពិសេស ពួក គេ បានគេចវេះ មិនព្រម និយាយ អំពី បញ្ហា ដកកង ទ័ព ឈ្លានពាន របស់គេ ចេញ ពី ទឹកដីខ្មែរ ដែល ជា កម្មវត្ថុ តែមួយ នៃ កិច្ចចរចា នោះទៀតផងៗ ពួកគេ បាន ឆ្លើយ ទាំងព្រហើនថា ទ័ពគេ ដែល ចូលមកតាំង លើ ទឹកដីខ្មែរនោះ គឺ បាន ទទួល សេចក្ដីអនុញ្ញាត ពី ស្ដេចសីហនុៗ នៅមុខ សភាព ការណ៍ ដ៏ធ្ងន់ធ្ងរ បែបនេះ ក្រុម អ្នកដឹកនាំខ្មែរ ពេលនោះ ក៏ បាន ធ្វើ សេចក្ដីរាយ ការណ៍ ផ្ញើ ទៅ ស្ដេចសីហនុ ដែល កំពុង ព្យាបាលរោគ នៅ ប្រទេសបារាំង ដើម្បី

ប្រាប់ អំពី ហេតុការណ៍ ដែល កើតឡើងៗ តែ គួរឲស្តាយ ក្នុង សាទូរលេខមួយ ច្បាប់ ផ្ញើ មក ពី ក្រុងប្ញារីស៍ តប មកអ្នកដឹកនាំ នៅក្នុង ប្រទេស វិញ សីហនុ មិន ត្រឹម តែ ចេញមុខ កាន់ជើង យួនខាងជើង និង យៀកកុង ថែម ទាំង បាន ចោទ ប្ញាតុករខ្មែរ ដែលប្រឆាំងនឹង វត្តមាន នៃទ័ពយៀកកុង យួនខាងជើង ក្នុងទឹកដីខ្មែរ ថា ជា ពួក « ក្បត់ជាតិ » ធ្វើ តាម ខ្សែ ញាក់ញុះញង់ របស់ ចក្រពត្តិអាមេរិកាំងៗ សីហនុ បាន ភ្លេច ថា ខ្លួន ជា ខ្មែរ ហើយ ភ្លេចនឹកគិត ដល់ ប្រយោជន៍ជាតិ ជា ធំ បែរ ទៅកាន់ជើង ពួកសត្រូវនឹង ប្រជារាស្ត្រខ្មែរ ទៅវិញៗ នៅ ចំពោះមុខ ឥរិយា បថ ក្បត់ជាតិ របស់ ស្តេចសីហនុ សភាទាំងពីរ គឺ រដ្ឋសភា និង ក្រុមព្រឹក្សារាជា ណាចក្រ រួមប្រជុំ នៅ ថ្ងៃ១៨ មីនា ១៩៧០ បាន ធ្វើ ការសម្រេចចិត្ត ជា ឯកច្ឆ ន្តប្រកាស ទម្លាក់ ស្តេចសីហនុ ចេញពី តំណែង ប្រមុខរដ្ឋ ស្របតាម មាត្រា ១២២ នៃ រដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៤៧ៗ

ដោយ ក្តៅក្រហាយនឹង ប្រជារាស្ត្រខ្មែរ តាម រយៈ នៃ សភា ទាំងពីរ ដែល បាន ទម្លាក់ ខ្លួន ចេញពី មុខតំណែង សីហនុ ក៏ បាន ផ្សាយសារមួយច្បាប់ ពី ក្រុង ប៉េ កាំង នៅ ថ្ងៃ២៣ មីនា ១៩៧០ អំពាវនាវ ហៅ កងទ័ពយួនខាងជើង យៀកកុង ដែល បាន មកតាំងទី ពាសពេញ លើ ទឹកដីខ្មែរ ស្រាប់ តាម ការសមគំនិត របស់ ខ្លួននោះ ឲបើក ការវាយប្រហារ ប្រទេសខ្មែរ ដើម្បី ជួយខ្លួន ឲវិលត្រឡប់ មកកាន់ អំណាចវិញៗ តាម សេចក្តីអំពាវនាវ ហៅ របស់ ស្តេចក្បត់ជាតិ ឈ្មោះសីហនុ ដែល ត្រូវ រាស្ត្រខ្មែរ ទម្លាក់ពី តំណែងនេះ ទ័ពយួនខាងជើង និង យៀកកុង ក៏បាន

ចាប់ផ្តើម បើក ការវាយប្រហារ យ៉ាងចេញមុខ និង យ៉ាងសាហាវ ព្រៃផ្សៃ ក្នុង ប្រទេសខ្មែរ តាំង ពី ថ្ងៃ២៩ មីនា ១៩៧០ រហូតមក។

ឥឡូវនេះ បួន ឆ្នាំ ប្លាយ កន្លងមកហើយ សីហានុ ឋិត នៅ ឯ ក្រុងប៉េកាំង ក្លាយ ខ្លួន ជា អាយ៉ង របស់ ក្រុងប៉េកាំង និង ក្រុងហាណូយ ដែល ទុក ប្រើប្រាស សំរាប់ ផែនការ ពង្រីក ទឹកដី និង មនោគមវិជ្ជា របស់គេ។ ចិនកុម្មុយនិស្ត និង យួនខាង ជើង បាន ផ្តល់លុយកាក់ និង ជំនួយ គ្រប់បែបយ៉ាង ដល់រដ្ឋាភិបាល និរទេស របស់ សីហានុ សំរាប់រស់។ គោលបំណង របស់ សីហានុ គឺ ចង់ វិលត្រឡប់ មកកាន់ អំណាចវិញ ក្រោម ការហែហម ការពារ នៃ ទ័ពយួនខាងជើង,យៀកកុង និង ក្រោម ក្លស់ប្ញាំង របស់ ចិនកុម្មុយនិស្ត ដោយ មាន ភ្លេងម៉ុងសាយ ហែ កំដរផង។ ក្នុង សម្ភាសន៏មួយ ដែល បាន ធ្វើ ជាមួយ អ្នកកាសែត ស្រី ជាតិអ៊ីតាលី ម្នាក់ ឈ្មោះ អូលីយ៉ាណា ហ្វាឡាស៊ី ហើយ ដែល ត្រូវ បាន កាសែត អឺរុប និង អាស៊ី ជាច្រើន លើក យក ទៅ ផ្សាយ ជាហូរហែ នៅដើម ខែ កញ្ញា ឆ្នាំ ១៩៧៣ សីហានុ បាន ប្រកាស ថា ខ្លួន ធ្វើ សង្គ្រាម ដើម្បី ឲប្រទេសខ្មែរ ក្លាយ ទៅ ជា ប្រទេស កុម្មុយនិស្ត តែ ក្នុង ពេល ជា មួយគ្នានោះ សីហានុ ក៏ បាន ប្រកាសដែរថា ប្រជារាស្ត្រខ្មែរ ជាង ៩០ ភាគរយ មិនមែន ជា កុម្មុយនិស្ត ទេ។

តើ សីហានុ អាច សម្រេច ដូច បំណង របស់ ខ្លួន ប្រៀបបាននឹង ការយល់សប្តិ រាវ ម្ទុល ក្នុង បាតសមុទ្រនេះបាន ដែរឬទេ ? នេះជា សំណួរ ដែលយើង សុំទុក ការ: ជូន មិត្ត អ្នកអាន ឆ្លើយ ដោយ ខ្លួនឯងទៅចុះ។ យើង គ្រាន់ តែ សូម រំលឹក ថានៅ

ឧប សៅ សង្ហា
២០ មេសា ២០១៦

ពេល ដេក យល់សប្តិ យ៉ាងនេះ សីហនុ ប្រាកដ ជា ភ្លេចនឹកគិត ថា ខ្លួន ត្រូវ គេ យក មក ប្រើប្រាស់ ក្នុង មួយរយ: ដើម្បី គ្រាន់ តែ ធ្វើ ជា ឡប់ខ្មៅ បិទបាំង នូវ ផែនការ ឈ្លានពាន របស់ ពួកកុម្មុយនិស្តឥណ្ឌូចិនប៉ុណ្ណោះៗ សីហនុ ភ្លេច គិតថា ខ្លួន ជា អ្វីហើយ ហើយ ភ្លេច គិត ថា « ប្រសិនបើ ប្រទេសខ្មែរ ក្លាយ ទៅ ជាកុម្មុយនិស្ត ដូច ការយល់សប្តិមែន » តើ ខ្លួន សីហនុ អាច ចូលចុះ ជា មួយនឹងពួក ខ្មែរក្រហម ដែល ក្រុងហាណូយ បានបណ្តុះបណ្តាល សំរាប់ចបំផើនយោបាយ ពង្រីក ទឹកដី និង មនោគមវិជ្ជា របស់គេ នោះដែរឬ ? អ្នកណា ក៏ នៅចាំ បានដែរ ថា កាល នៅ កាន់អំណាចផ្តាច់ការ សីហនុ ធ្លាប់ ចាត់ ទុកពួក ខ្មែរក្រហម ជា ពួក ជន « ក្បត់ជាតិ » ថា ជា សត្រូវ ស្លាប់រស់ របស់ខ្លួន ដែល មិនអាច រស់ នៅក្រោម ដំបូល តែមួយបានៗ ក្នុង សារ ថ្លែង តាមវិទ្យុ កាល ពី ថ្ងៃ៨តុលា ១៩៦៨ សីហនុ កាលនៅ ជា ប្រមុខរដ្ឋ បាន និយាយ ទៅ កាន់ អស់លោកហ៊ូ នឹម, ហ៊ូ យន់, ខៀវ សំផន, គោត ឆាយ ហើយ និងបក្សពួកថា៖ « .ខ្ញុំសីហនុនឹងប្រយុទ្ធ ប្រឆាំងទល់ នឹង អស់លោក ទាំងនោះ រហូត ដល់ ទីបញ្ចប់, រហូតដល់ ពេលណា ធ្វើ ឲផុត កំពូជ ខ្មែរ ដែល មិនមែនខ្មែរ, ទោះបី សីហនុខ្ញុំ ត្រូវ ស្លាប់ ក៏ដោយ... »ៗ

តាមពិត សីហនុ ប្រាកដ ជា នៅ ចាំ ពាក្យ សំដី ទាំងនេះ របស់ខ្លួន ជាង នរណា ទាំងអស់ៗ ក៏ប៉ុន្តែ សីហនុ ត្រូវ ក្បត់សំដីឯង យក ការយល់សប្តិ ជា ការពិត ហើយ សុខចិត្ត លេប គ្រាប់ត្រួស ជំនួស គ្រាប់ស្ករ ជា ជាង នៅ មាត់ទំនេរៗ សីហនុ ដឹង ច្បាស់ ថា ខ្លួន នឹងត្រូវគេបោះបង់ចោល នៅ ពេលណា ពួក កុម្មុយនិស្ត សម្រេច

នូវ គោលបំណង របស់គេ ហើយៗ ក៏ ប៉ុន្តែ ដោយ គំនិ របស់ ខ្លួន ចង់ សងសឹក ប្រជារាស្ត្រខ្មែរ ដែល បាន ទម្លាក់ខ្លួន ពី មុខតំណែង សីហនុ ក៏ ពេញចិត្ត ធ្វើ ឡប់ខ្មៅ បិទបាំង នូវ គំរោង ការឈ្លានពាន របស់ ពួកកុម្មុយនិស្តឥណ្ឌូចិន ទោះបី ដឹង ថា ខ្លួន ពុំអាចវិលត្រឡប់ មក កាន់អំណាច វិញ ក៏ដោយៗ

ក្នុង សង្គ្រាម ឈ្លានពាន ដែល កុម្មុយនិស្តឥណ្ឌូចិន បាន យក ឈ្មោះ សីហនុ មក ធ្វើ ជា ឡប់ខ្មៅនេះ ពួក គេ បាន ឃោសនា បោកប្រាស មតិអន្តរជាតិ ថា ជា « សង្គ្រាម រំដោះ ទឹកដីខ្មែរ ពី កណ្តាប់ដៃ នៃ ចក្រពត្តិអាមេរិកាំង »(sic) ការឃោសនា ទុចរិតនេះ ជា ដំបូង បានធ្វើ ឲមតិសាធារណ: មួយភាគ តូច ដែល កំពុង បាន ដឹង ការពិត ឬ មិន ព្រមទទួលការពិត មាន ការយល់ច្រឡំ ជឿ តាម ទាំង ងងិតងងល់ៗ តែ ទី បំផុត ការពិត នៅតែ ជា ការពិត ដែល ពុំ អាច លាក់ បំបាំងបានៗ ក្នុង រយ: ពេល ៨ ឆ្នាំ កន្លងមកនេះ មតិ អន្តរជាតិ កាន់ តែ យល់ដឹង នូវ ការពិត នេះ គឺ សង្គ្រាម ដែល កើតឡើង នៅ ក្នុងស្រុកខ្មែរ រហូត មក ដល់ពេលនេះ ជា សង្គ្រាម ឈ្លានពាន ដែល ពួក កុម្មុយនិស្តឥណ្ឌូចិន មាន យួនខាងជើង ជា មេក្លោង បង្កឡើង, ក្នុង គោលបំណង ជ្រលក់ ក្រហម ទឹកដីខ្មែរ បង្ខំ ឲរាស្ត្រខ្មែរ ទទួល យក នូវ របប មនោគមវិជ្ជាមួយ ដែល រាស្ត្រខ្មែរ ពុំ ចង់ បាន ទាល់ តែ សោះៗ នេះ ជា គម្រោងការ របស់ ពួក បរទេស ឈ្លានពាន ក្នុង ដំណាក់ការ ទី ១ៗ នៅ ដំណាក់ការ ទី២ គឺ កាលណា ជ្រលក់ ក្រហមទឹកដីខ្មែរហើយ ពួក ឈ្លានពាន នឹងអនុវត្ត បណ្តាំ របស់ ខ្មោចហូជីមិញ គឺ បញ្ចូល ប្រទេស ទាំង៣ នៅ

អតីតឥណ្ឌូចិន ទៅក្នុង « សហព័ន្ធកុម្មុយនិស្តឥណ្ឌូចិន » ក្រោម ការត្រួតត្រាផ្ទាល់ របស់ ក្រុងហាណូយៗ ពេលនោះហើយ ដែល មាតុភូមិខ្មែរ ប្រជាជាតិខ្មែរ ពូជសាសន៍ខ្មែរនិង ព្រះពុទ្ធសាសនា នឹងត្រូវ រលាយសាបសូន្យ បាត់ឈ្មោះ ពីពិភពលោកៗ

ទាំងនេះហើយ ដែល ជា មូលហេតុ ជា លក្ខណៈ និង គោលដៅ នៃ សង្គ្រាម ដែល ពួក កុម្មុយនិស្តឥណ្ឌូចិន បាន បង្កឡើង នៅ ក្នុង ស្រុកខ្មែរ ក្នុង រយៈពេល ជាង ៨ ឆ្នាំ កន្លងទៅនេះៗ៚

ថាច់ តែន

ឧប សៅ សង្ហា
២០ មេសា ២០១៦